**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបុណ្យរំលឹកលោកឪពុកប៉ូហៀប**
**ផ្លូវត្រី ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩**
**សូមជួយខ្ញុំឲ្យខ្ញុំនៅជាមនុស្សសុចរិត**

**អត្ថបទទី១៖ អេសាយ ៥៥,១០-១១**
រីឯពាក្យរបស់យើងក៏ដូច្នោះដែរ គឺពាក្យដែលចេញពីមាត់របស់យើង នឹងមិនវិលត្រឡប់មករកយើងវិញទេ ដរាបណាទាល់តែបានសម្រេច តាមបំណងរបស់យើងជាមុនសិន គឺបំពេញកិច្ចការដែលយើងចាត់ឲ្យមកធ្វើ រួចរាល់សព្វគ្រប់។ អស ៥៥,១១
**អត្ថបទទី២៖ រ៉ូម ៥,១-១១**
ការអត់ធ្មត់នាំឲ្យយើងចេះស៊ូទ្រាំ ហើយការស៊ូទ្រាំនាំឲ្យយើងមានសេចក្ដីសង្ឃឹម។ រម ៥,៤
**ដំណឹងល្អ៖ ម៉ាថាយ ៦,៧-១៥**
បើអ្នករាល់គ្នាអត់ទោសឲ្យមនុស្សលោក ព្រះបិតារបស់អ្នករាល់គ្នានៅស្ថានបរមសុខ ក៏អត់ទោសឲ្យអ្នករាល់គ្នាដែរ។ មថ ៦,១៤

បងប្អូនជាទីស្រឡាញ់!

សូមស្វាគមន៍លោកបូជាចារ្យ បងប្រុសបងស្រី បងប្អូនគ្រីស្តបរិស័ទទាំងអស់ដែលមកពីប្រទេសវៀតណាមនិងប្រទេសកម្ពុជាយើង។ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៤៦ ជាថ្ងៃដែលលោកឪពុកប៉ូហៀបបានទទួលមរណភាព។ បងប្អូនមួយចំនួនមកថ្ងៃនេះ ដើម្បីចង់បានវាសនាពិសេសសម្រាប់ជីវិត។ ថ្ងៃនេះជាថ្ងៃពិសេស ដោយថ្ងៃទី១២ គឺមួយបូកពីរស្មើបី ខែមីនា គឺបី ឆ្នាំ២០១៩ គឺពីរបូកសូន្យបូកមួយបូកប្រាំបួនស្មើដប់ពីរ គឺមួយបូកពីរស្មើបី គឺមានន័យថាឆ្នាំនេះយើងមានលេខ៣បីដងពិសេសបំផុតសរុបមកគឺលេខប្រាំបួន។

ប៉ុន្មានខែមុននៅទីក្រុងរ៉ូម គេបានឲ្យខ្ញុំផ្តល់សក្ខីភាពអំពីលោកឪពុកប៉ូហៀប ខ្ញុំបានប្រាប់ថាមួយឆ្នាំម្តងយើងបានមកជួបជុំគ្នានៅផ្លូវត្រីនេះយ៉ាងច្រើន ដើម្បីបង្ហាញអំពីសេចក្តីស្រឡាញ់ដែលយើងមានចំពោះលោកឪពុកប៉ូហៀប។ នៅឆ្នាំ១៩២៤ លោកឪពុកប៉ូហៀបបានទទួលខុសត្រូវព្រះសហគមន៍ផ្លូវត្រីនេះ គាត់បានរៀននៅទេវវិទ្យាល័យនៅផ្សារតូចពីដើម។ សព្វថ្ងៃនៅប្រទេសវៀតណាម គេកំពុងកាត់ក្តីគាត់ដើម្បីឲ្យគាត់អាចក្លាយជាសន្តបុគ្គលជាផ្លូវការណ៍ ដូច្នេះគេសួរយោបល់ខ្ញុំដែលជាអភិបាលភូមិភាគភ្នំពេញ។ នៅពេលខ្ញុំផ្តល់សក្ខីភាពអំពីរបៀបដែលយើងបានមកជួបជុំគ្នានៅទីនេះប៉ុន្មានឆ្នាំហើយ ដូចជាគេភ្ញាក់ នៅរ៉ូមគេចាប់អារម្មណ៍អំពីរបៀបដែលយើងគោរពលោកឪពុកប៉ូហៀបនៅប្រទេសកម្ពុជា។ ឥឡូវនេះ គេបានបើកការស៊ើបអង្កេត

ដើម្បីកាត់ក្តីគាត់ឲ្យធ្វើជាសន្តនៅថ្ងៃអនាគត។ លោកឪពុកប៉ូហៀបប្លែក គាត់មិនទាន់ក្លាយទៅជាសន្តប៉ុន្តែបងប្អូនគោរពគាត់ខ្លាំងណាស់ ជាពិសេសនៅតាមផ្ទះបងប្អូនវៀតណាមគឺមានរូបលោកឪពុកស្ទើរគ្រប់ផ្ទះ។

ក្នុងអត្ថបទទីពីរ "**ដូច្នេះដោយព្រះជាម្ចាស់ប្រោសយើងឲ្យបានសុចរិត ព្រោះតែយើងមានជំនឿ**" ថ្ងៃនេះយើងមកគោរពឪពុកប៉ូហៀប ដោយសារគាត់ជាមនុស្សសុចរិត ដោយសារគាត់មានជំនឿ។ គេបានសម្លាប់គាត់នៅឆ្នាំ១៩៤៦ មានន័យថាពេលគាត់ទៅប្រទេសវៀតណាម គាត់បានរងទុក្ខយ៉ាងខ្លាំងរហូតដល់ទទួលមរណភាព។ អត្ថបទទីពីរ "**ទុក្ខវេទនានឹងនាំឲ្យយើងចេះអត់ធ្មត់ អត់ធ្មត់នាំឲ្យយើងចេះស៊ូទ្រាំ ស៊ូទ្រាំនាំឲ្យយើងមានសេចក្តីសង្ឃឹម**" នេះជាគំរូសម្រាប់ជីវិតរបស់យើង ជាពិសេសនៅក្នុងរដូវ៤០ថ្ងៃ យើងដឹងថារដូវ៤០ថ្ងៃជាពេលវេលាដើម្បីកែប្រែចិត្តគំនិត ដើម្បីទៅជាមនុស្សសុចរិតថែមទៀត ដើម្បីចូលនៅក្នុងជីវិតថ្មីរួមជាមួយព្រះយេស៊ូ។

កាលពីថ្ងៃអាទិត្យភូមិភាគភ្នំពេញយើងបានទទួល១៥៤នាក់ ដែលបានទទួលការត្រាស់ហៅយ៉ាងឱឡារិកពីព្រះសហគមន៍ ដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹកក្លាយជាគ្រីស្តបរិស័ទ មានន័យថាកើតជាថ្មីនៅរាត្រីបុណ្យចម្លងខាងមុខ។ ប៉ុន្តែ យើងទាំងអស់ដែលជាគ្រីស្តបរិស័ទក៏ដូចគ្នាដែរ រដូវ៤០ថ្ងៃជាពេលវេលា ដើម្បីកើតជាថ្មីទៅជាមនុស្សសុចរិតដូចលោកឪពុកប៉ូហៀបពីដើម។ នៅក្នុងជីវិតយើងទាំងអស់គ្នា យើងមានទុក្ខវេទនា មានការពិបាកចិត្ត ប៉ុន្តែដោយសារយើងមានព្រះយេស៊ូ និងរដូវ៤០ថ្ងៃជាពេលវេលាដើម្បីសម្លឹងមើលព្រះយេស៊ូនៅលើឈើឆ្កាង យើងដឹងថាយើងមានព្រះយេស៊ូដែលយើងអាចទីពឹងលើព្រះអង្គ និងណែនាំឲ្យយើងចេះតស៊ូ និងមានចិត្តអត់ធ្មត់នៅក្នុងជីវិតរបស់យើងដើម្បីទៅមុខទៀត។ ក្នុង១៥៤នាក់ ក្នុងភូមិភាគភ្នំពេញដែលនឹងទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងរាត្រីបុណ្យចម្លងខាងមុខនេះ យើងមានទាំងយាយចាស់ៗ យើងមានទាំងអ្នកជំងឺអេដស៍ យើងមានទាំងមនុស្សគរថ្លង់ យើងមានទាំងជនពិការ... នេះជាសញ្ញាសម្គាល់ដែលយើងបានទទួលសេចក្តីស្រឡាញ់ពីព្រះសហគមន៍ ពីព្រះជាម្ចាស់ជីវិតរបស់យើងអាចរស់នៅតាមរបៀបថ្មី ដោយសារយើងមានសេចក្តីសង្ឃឹម។

ដូច្នេះសម្រាប់បងប្អូនទាំងអស់ ដែលបានចូលរួមថ្ងៃនេះយើងរួមគ្នាទូលអង្វរលោកឪពុកប៉ូហៀប ឲ្យគាត់ជួយយើងដើម្បីឲ្យយើងទៅជាមនុស្សថ្មី មនុស្សសុចរិតដែលចេះបង្ហាញសេចក្តីសង្ឃឹម បើកផ្លូវសម្រាប់បងប្អូនឯទៀតនៅក្នុងសង្គមបច្ចុប្បន្ននេះ។ យើងចង់រកឃើញសុភមង្គល និងសេចក្តីសុខសាន្ត យើងមិនរកឃើញនៅក្នុងលេខប្រាំបួនដែលខ្ញុំបាននិយាយនោះទេ សុភមង្គលនិងសេចក្តីសុខសាន្តយើងអាចរកឃើញនៅក្នុងព្រះយេស៊ូគ្រីស្តជាអម្ចាស់។ ហេតុនេះហើយ ឲ្យយើងបើកភ្នែកនិងត្រចៀករបស់យើងយ៉ាងធំ ដើម្បីស្តាប់ព្រះសូរសៀងរបស់ព្រះយេស៊ូ

និងដើម្បីមើលឃើញព្រះយេស៊ូនៅគ្រប់ទីកន្លែង ជាពិសេសនៅក្នុងបងប្អូនឯទៀតៗដែលកំពុងមានទុក្ខលំបាក។ ថ្ងៃនេះយើងសុខចិត្តឈប់សម្រាក ថ្ងៃនេះយើងសុខចិត្តខាតមិនរកស៊ី យើងមកទីនេះដើម្បីទទួលជំនឿថែមទៀតឲ្យអនាគតរបស់យើងទៅជាមនុស្សសុចរិតដូចលោកឪពុកប៊ូហៀបដែរ។ នៅពេលយើងចេញធ្វើដំណើរ ឲ្យយើងឈប់មួយភ្លែតនៅមុខរូបសំណាកលោកប៊ូហៀប ដោយអធិដ្ឋានថា "**ឱព្រះអម្ចាស់អើយ! ដែលពោរពេញដោយធម៌មេត្តាករុណា សូមជួយខ្ញុំឲ្យខ្ញុំទៅជាមនុស្សសុចរិតដូចលោកឪពុកប៊ូហៀបផង**"។ អាម៉ែន៕